[បកប្រែក្រៅផ្លូវការ]

ភ្នំពេញ ថ្ងៃទី ខែ កុម្ភៈ ឆ្នាំ ២០១៨

ឯកឧត្តម ស៊ីនហ្សូ អាបេ
នាយករដ្ឋមន្ត្រីជប៉ុន
ក្រុងតូក្យូ

ឯកឧត្តម

តាងនាមរាជរដ្ឋាភិបាល និងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសំដែងនូវការអបអរសាទរដ៏កក់ក្តៅបំផុតជូនចំពោះឯកឧត្តម និងតាមរយៈឯកឧត្តមជូនចំពោះរដ្ឋាភិបាល និងប្រជាជនជប៉ុនជាមិត្ត ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៦៥នៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជា និងជប៉ុន។

ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយបានកត់សម្គាល់ឃើញថា ទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការដ៏ប្រសើរដែលជាក្តីប្រាថ្នារួមរបស់ប្រជាជាតិយើងកាលពី៦៥មុន ទោះជាបានឆ្លងកាត់ពេលវេលា និងការប្រែប្រួលស្ថានភាពក្នុងតំបន់ និងអន្តរជាតិ មិនត្រឹមតែនៅរក្សាបានល្អប៉ុណ្ណោះទេ តែថែមទាំងមាននិន្នាការរីកចម្រើន និងមានភាពកាន់តែស៊ីជម្រៅទៀតផង។ ក្នុងទសវត្សរ៍១៩៩០ ជប៉ុនបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការសន្តិភាពនៅកម្ពុជា ដោយរួមទាំងការបញ្ជូនកម្លាំងថែរក្សាសន្តិភាពក្រោមក្របខ័ណ្ឌអង្គការសហប្រជាជាតិ ជាលើកទី១ មកប្រទេសកម្ពុជា។ រដ្ឋាភិបាល និងប្រជាជនជប៉ុនក៏បានរួមចំណែកយ៉ាងធំធេងដល់ការស្តារឡើងវិញក្រោយពីជម្លោះ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រទេសកម្ពុជា ដូចឃើញសព្វថ្ងៃ។

រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាអរគុណ និងវាយតម្លៃខ្ពស់ចំពោះការគាំទ្រដ៏ថ្លៃថ្លារបស់ជប៉ុនដែលបានជួយប្រែក្លាយកម្ពុជាពីប្រទេសដែលត្រូវហែកហួរដោយសង្គ្រាម និងជាប្រទេសទទួលកម្លាំងរក្សាសន្តិភាពអង្គការសហប្រជាជាតិ ឲ្យទៅជាប្រទេសដែលមានសេដ្ឋកិច្ចរីកលូតលាស់លឿនបំផុតមួយក្នុងពិភពលោក និងជាអ្នករួមចំណែកយ៉ាងសកម្មក្នុងការរក្សាសន្តិភាពអន្តរជាតិ។ ខ្ញុំរីករាយដោយបានឃើញនូវកំណើនវិសាលភាព និងជម្រៅនៃកិច្ចសហប្រតិបត្តិការលើវិស័យជាច្រើនរវាងកម្ពុជា និងជប៉ុន ដែលជាមូលដ្ឋានធ្វើឲ្យទំនាក់ទំនងរបស់ប្រទេសយើងត្រូវបានលើកកម្ពស់ទៅជាដៃគូយុទ្ធសាស្ត្រកាលពីឆ្នាំ២០១៣។ ការផ្លាស់ប្តូរទស្សនកិច្ចជាន់ខ្ពស់ រួមទាំងទស្សនកិច្ចរបស់ខ្ញុំនៅជប៉ុនកាលពីខែសីហាឆ្នាំទៅ កំណើនពាណិជ្ជកម្ម និងវិនិយោគ ការប្រាស្រ័យទាក់ទងរវាងប្រជាជននិងប្រជាជនក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ បានពង្រឹងឲ្យកាន់តែរឹងមាំថែមទៀតនូវខ្សែទំនាក់ទំនាក់យូរអង្វែងរវាងប្រជាជាតិយើងទាំងពីរ។

ខណៈដែលការប្រារព្ធខួបទំនាក់ទំនងការទូតរវាងប្រទេសយើងនៅឆ្នាំនេះ ពិតជានឹងបង្កើនកម្លាំងស្មារតីមិត្តភាព និងសហប្រតិបត្តិការរវាងប្រជាជនយើងទាំងពីរ ខ្ញុំត្រៀមខ្លួនធ្វើការជាមួយឯកឧត្តមដើម្បីបន្តពូនជ្រុំ និងលើកស្ទួយចំណងមិត្តភាពដ៏កក់ក្តៅរបស់យើងឲ្យកាន់តែខ្ពស់ឡើងទៀត។

ខ្ញុំសូមឯកឧត្តមទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់ និងសូមជូនពរឯកឧត្តមសូមប្រកបដោយសុខភាពបរិបូណ៌ និងជោគជ័យ និងសូមឲ្យប្រជាជនជប៉ុនមានសុភមង្គល និងវិបុលភាពកាន់តែធំធេង។

**ហ៊ុន សែន**